# សេចក្តីប្រកាសព័ត៌មាន

## អូស្ត្រាលីផ្តល់ថវិកា ៤ លានដុល្លារអូស្ត្រាលីបន្ថែមទៀត ដើម្បីពង្រឹងភាពធន់ និងការឆ្លើយតបរបស់កម្ពុជា ចំពោះវិបត្តិកូវីដ-១៩

**រាជធានីភ្នំពេញ ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២១៖** រដ្ឋាភិបាលអូស្ត្រាលីបានចុះកិច្ចព្រមព្រៀងមួយជាមួយនឹង កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ដើម្បីផ្តល់ថវិកា ៤ លានដុល្លារអូស្ត្រាលីបន្ថែមទៀត សម្រាប់កាត់បន្ថយផលប៉ះពាល់នៃជំងឺកូវីដ-១៩ មកលើសេដ្ឋកិច្ច និងពលរដ្ឋកម្ពុជា។ កិច្ចព្រមព្រៀងនេះនឹងចាប់ផ្តើមអនុវត្តភ្លាមៗតែម្តង។

ថវិកាដែលផ្តល់នេះ គឺជាថវិកាបន្ថែមលើមូលនិធិពង្រឹងភាពធន់របស់អូស្ត្រាលី-UNDP ជាយន្តការមួយប្រកបដោយភាពទន់ភ្លន់ ដែលបាននឹងកំពុងផ្តល់ការគាំទ្រដល់កម្ពុជា ក្នុងការឆ្លើយតប និងស្តារផលប៉ះពាល់សង្គមសេដ្ឋកិច្ច ដែលបង្កឡើងដោយសារការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩។

គិតរហូតមកដល់ពេលបច្ចុប្បន្ននេះ មូលនិធិនេះបានបំពេញតួនាទីយ៉ាងសំខាន់ ក្នុងការពង្រីកការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ ដែលកម្ពុជាកំពុងអនុវត្ត ហើយដែលកន្លងមកបានផ្តល់សាច់ប្រាក់ចំនួន ២៩០ លានដុល្លារសហរដ្ឋអាមេរិក ដល់ប្រជាពលរដ្ឋទីទ័លក្រប្រមាណ ៦៩៣ ០០០ គ្រួសារនៅកម្ពុជាក្នុងអំឡុងពេលនៃការរាតត្បាតជាសកលនេះ។ ជាឧទាហរណ៍ អូស្ត្រាលីនិងUNDP បានផ្តល់ការគាំទ្រដល់កម្មវិធីដ៏មានសារៈសំខាន់មួយនេះ របស់រាជរដ្ឋាភិបាលកម្ពុជាតាមរយៈការធ្វើលទ្ធកម្មឧបករណ៍ថាប្លេតចំនួន១៧០០គ្រឿង សម្រាប់ប្រើប្រាស់ក្នុងការកំណត់អត្តសញ្ញាណប្រជាពលរដ្ឋ រាប់សែនគ្រួសារដែលរងផលប៉ះពាល់ដោយសារជំងឺកូវីដ-១៩ ដើម្បីឱ្យពួកគេអាចទទួលបានការឧបត្ថម្ភគាំទ្រនានា។ មូលនិធិនេះក៏បានធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជុំវិញការបង្កើតគំរូសម្រាប់ព្យាករណ៍ និងវិភាគលើផលប៉ះពាល់នៃកូវីដ-១៩ ដើម្បីផ្តល់ជាព័ត៌មាន សម្រាប់ការដាក់ចេញនូវកញ្ចប់ថវិកាសង្គ្រោះ សម្រាប់ជួយដល់អ្នកដែលងាយរងគ្រោះជាងគេ។

មូលនិធិពង្រឹងភាពធន់នេះបានជួយសម្រួល ឱ្យមានការបន្តការធ្វើពាណិជ្ជកម្មឆ្លងដែនប្រកបដោយសុវត្ថិភាព តាមរយៈការផ្តល់នូវឧបករណ៍ការពារ និងសម្ភារអនាម័យសំខាន់ៗ ដល់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។ មូលនិធិនេះ ក៏បានជួយឱ្យអាជីវកម្មខ្នាតតូច អាចតភ្ជាប់ទំនាក់ទំនងជាមួយនឹងទីផ្សារពាណិជ្ជកម្មអេឡិចត្រូនិកតាមអ៊ីនធឺណេត ដើម្បីឱ្យអាជីវកម្មទាំងនេះនៅតែអាចបន្តដំណើរការរបស់ខ្លួន ក្នុងអំឡុងពេលដែលមានការអនុវត្តវិធានការបិទខ្ទប់ទីក្រុង និងមានលទ្ធភាពចូលប្រឡូកក្នុងសេដ្ឋកិច្ចឌីជីថលក្នុងរយៈពេលវែង។

**លោក Nick Beresford នាយក UNDP ប្រចាំកម្ពុជា** មានប្រសាសន៍ថា «អូស្ត្រាលី គឺជាប្រទេសដែលនាំមុខគេក្នុងការផ្តល់ជំនួយអភិវឌ្ឍន៍យ៉ាងមានប្រសិទ្ធភាព និងទាន់ពេលវេលា ហើយប្រទេសអូស្ត្រាលីបានធ្វើបែបនេះ តាមរយៈកម្មវិធីវៃឆ្លាត ដែលបត់បែនទៅតាមកាលៈទេសៈជាក់ស្តែង។ រួមគ្នាយើងអាចឆ្លើយតបបានយ៉ាងលឿនចំពោះវិបត្តិនេះ តាមរយៈការគាំទ្រដល់ការពង្រីកកម្មវិធីជំនួយសង្គម ឱ្យបានឆាប់រហ័សដើម្បីឱ្យជំនួយឧបត្ថម្ភនានា បានដល់គ្រួសារដែលត្រូវការជំនួយជាងគេ ហើយក្នុងពេលជាមួយគ្នាក៏ការពារដំណើរការពាណិជ្ជកម្ម និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋផងដែរ។»

**ឯកឧត្តម Pablo Kang ឯកអគ្គរាជទូតអូស្ត្រាលីប្រចាំកម្ពុជា** មានប្រសាសន៍ថា «កូវីដ-១៩ នាំមកនូវបញ្ហាប្រឈមបន្ទាន់ចំពោះមុខជាច្រើន ដល់សេដ្ឋកិច្ចកម្ពុជា ក៏ដូចជាជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ក្នុងនាមជាដៃគូ និងមិត្តភ័ក្រ្តយូរអង្វែងរបស់ប្រទេសនេះ យើងចង់ធ្វើអ្វីដែលអាចធ្វើទៅបាន ដើម្បីសម្រាលផលប៉ះពាល់ទាំងនេះ ជាពិសេសផលប៉ះពាល់មកលើក្រុមមនុស្សដែលងាយរងគ្រោះជាងគេ។ តាមរយៈការសហការជាមួយនឹង UNDP យើងក៏កំពុងបង្កើនថវិកាគាំទ្រ សម្រាប់ការងារដែលចាំបាច់នៅពេលបច្ចុប្បន្ន ដើម្បីជួយកម្ពុជាក្នុងការត្រៀមស្តារសេដ្ឋកិច្ចឡើងវិញឱ្យបានឆាប់រហ័ស ប្រកបដោយបរិយាបន្ន បន្ទាប់ពីការរាតត្បាតជាសកលនេះ។»

ថវិកា៤លានដុល្លារអូស្ត្រាលីបន្ថែមនេះ នឹងត្រូវប្រើប្រាស់សម្រាប់បន្តការអនុវត្តការងារ ពង្រឹងកម្មវិធីជំនួយសង្គម និងគាំទ្រដល់អាជីវកម្មនៅក្នុងស្រុក ដើម្បីសម្របខ្លួនទៅស្ថានភាពដែលពួកគេជួបប្រទះ ក្នុងអំឡុងពេលដែលមានការរាតត្បាតជាសកលនៃជំងឺនេះ ព្រមទាំងអាទិភាពដទៃទៀតដែលនឹងត្រូវកំណត់ តាមរយៈការពិគ្រោះយោបល់ជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា និងសង្គមស៊ីវិល។

***For media inquiries**, please contact:*

- *Australian Embassy Cambodia at Australian.Embassy.Cambodia@dfat.gov.au*
- *Mr. Im Samruol, Head of Communications, UNDP Cambodia at samruol.im@undp.org*

***UNDP** is the United Nations' global development network and is the leading United Nations organization fighting to end the injustice of poverty, inequality, and climate change. Working in 170 countries, we help nations to build integrated, lasting solutions for people and planet. Learn more at https://www.kh.undp.org/ or follow us at @UNDPCambodia.*

*The **Australian Government** is a longstanding development partner to Cambodia, contributing AU$71.5 million in support in 2020-21 through our COVID-19 Development Response Plan for Cambodia. Follow the embassy at @AustralianEmbassyPhnomPenh.*